# ការធ្វើតេស្តរកជំងឺ COVID-19 ខ្លួនអ្នក

ការប្រើប្រាស់កញ្ចប់ឧបករណ៍ធ្វើតេស្តដោយខ្លួនឯង គឺជាវិធីដែលឆាប់រហ័ស និងងាយស្រួលក្នុងការពិនិត្យមើលថាតើអ្នកមានជំងឺ COVID-19 ដែរឬអត់។ ការធ្វើតេស្តដោយខ្លួនអ្នក អាចនឹងមិនច្បាស់លាស់ដូចការធ្វើតេស្តដោយអ្នកជំនាញដែលបានទទួលការបណ្តុះបណ្តាលទេ។ ប៉ុន្តែការប្រើប្រាស់ធ្វើតេស្តដោយខ្លួនឯងគឺជាជម្រើសមួយ ប្រសិនបើអ្នកមិនអាចទៅដល់ទីតាំងធ្វើតេស្តបាន។ ត្រូវអនុវត្តតាមការណែនាំប្រើប្រាស់របស់ឧបករណ៍ធ្វើតេស្តឲ្យបានច្បាស់លាស់។

## ពេលដែលត្រូវប្រើឧបករណ៍ធ្វើតេស្តរកជំងឺ COVID-19 ដោយខ្លួនឯង

**ធ្វើតេស្តខ្លួនអ្នក** មុនពេលជួបជុំគ្នាក្នុងអគារជាមួយអ្នកដទៃជាពិសេសជាមួយអ្នកដែលមិនបានចាក់វ៉ាក់សាំង មានប្រព័ន្ធភាពសាំខ្សោយ ឬប្រឈមនឹងហានិភ័យខ្ពស់ក្នុងការមានជំងឺធ្ងន់ធ្ងរ។

**ធ្វើតេស្តខ្លួនអ្នក ប្រសិនបើអ្នកមាន [រោគសញ្ញានៃជំងឺ COVID-19](#)** ហើយមិនអាចទៅដល់ទីតាំងធ្វើតេស្តបាន។ នៅផ្ទះ និងនៅឆ្ងាយពីអ្នកដទៃ ប្រសិនបើអ្នកឈឺ។

## ប្រការដែលត្រូវអនុវត្តបន្ទាប់ពីធ្វើតេស្តរកជំងឺ COVID-19 ខ្លួនអ្នកហើយ

### ➕ ប្រសិនបើការធ្វើតេស្តរបស់អ្នកមានលទ្ធផលវិជ្ជមានវាមានន័យថាការធ្វើតេស្តបានរកឃើញវីរុស

ហើយអ្នកទំនងជាមានលទ្ធភាពខ្ពស់ក្នុងការមានជំងឺ COVID-19 ។ ស្នាក់នៅផ្ទះ (ដាច់ដោយឡែកពីអ្នកដទៃ) យ៉ាងហោចណាស់ 10ថ្ងៃ។ អ្នកដែលមានជំងឺ COVID-19 ត្រូវដាក់ឲ្យនៅដាច់ដោយឡែកពីអ្នកដទៃ បើទោះជាពួកគេមិនមានរោគសញ្ញាក៏ដោយ។ សម្រាប់ព័ត៌មានបន្ថែមអំពីការដាក់ឲ្យនៅដាច់ដោយឡែកពីអ្នកដទៃ សូមចូលទៅកាន់ **covid.ri.gov/whattodo**។

មានវិធីព្យាបាលដែលមានប្រសិទ្ធភាពសម្រាប់ការឆ្លងជំងឺ COVID-19 ។ អ្នកផ្តល់សេវាថែទាំសុខភាពអាចព្យាបាលជំងឺ COVID-19 របស់អ្នក ដោយផ្អែកលើលទ្ធផលធ្វើតេស្តដោយខ្លួនឯង។ ពួកគេអាចនឹងធ្វើតេស្តអ្នកម្តងទៀតដើម្បីប្រាកដថាលទ្ធផលធ្វើតេស្ត ដោយខ្លួនឯងគឺត្រឹមត្រូវ។ សម្រាប់ព័ត៌មានបន្ថែមអំពីការព្យាបាល សូមចូលទៅកាន់ **covid.ri.gov/treatment**។

សូមទូរសព្ទទៅលេខ 911 ឬធ្វើដំណើរទៅកាន់មន្ទីរពេទ្យដែលនៅជិតអ្នកបំផុត ប្រសិនបើអ្នកគិតថាអ្នកកំពុងត្រូវការការសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ។ នេះអាចមានដូចជាការពិបាកដកដង្ហើម ការឈឺចាប់ឬការតឹងណែនទ្រូងមិនធូរស្បើយ ការវង្វេងស្មារតីនាពេលថ្មីៗ មិនអាចភ្ញាក់ឬផ្ទង់ស្មារតីបាន ឬបបូរមាត់ឬមុខប្រែពណ៌ខៀវ។

### ➖ ប្រសិនបើការធ្វើតេស្តដោយខ្លួនឯងមានលទ្ធផលអវិជ្ជមានវាមានន័យថាការធ្វើតេស្តនោះរកមិនឃើញវីរុស។

- ប្រសិនបើអ្នកបានធ្វើតេស្តខណៈពេលដែលអ្នកមានរោគសញ្ញា ហើយបានធ្វើតាមការណែនាំទាំងអស់ដោយប្រុងប្រយ័ត្ន លទ្ធផលតេស្តអវិជ្ជមាននោះមានន័យថា ជំងឺបច្ចុប្បន្នរបស់អ្នកប្រហែលជាមិនមែនជំងឺ COVID-19 ទេ។
- អ្នកដែលមានជំងឺ COVID-19 អាចទទួលបានលទ្ធផលធ្វើតេស្តអវិជ្ជមាននៅលើការធ្វើតេស្តដោយខ្លួនឯង។ លទ្ធផលនេះហៅថាតេស្តដែលមានលទ្ធផលមិនត្រឹមត្រូវ។ អ្នកក៏អាចធ្វើតេស្តរកឃើញលទ្ធផលអវិជ្ជមានផងដែរ ប្រសិនបើគំរូសំណាកត្រូវប្រមូលយកនៅដំណាក់កាលដំបូងនៃការឆ្លងរបស់អ្នក។

### ❓ ប្រសិនបើអ្នកគិតថាលទ្ធផលធ្វើតេស្តរកជំងឺ COVID-19 ដោយខ្លួនឯង

អាចនឹងមិនត្រឹមត្រូវអ្នកគួរតែធ្វើតេស្តខ្លួនអ្នកម្តងទៀតក្នុងរយៈពេលពីរបីថ្ងៃ ដោយមានរយៈពេលយ៉ាងហោចណាស់ 24ម៉ោងនៅចន្លោះការធ្វើតេស្ត។ អ្នកក៏អាចធ្វើតេស្តមួយផ្សេងទៀតនៅទីតាំងធ្វើតេស្តគ្រប់គ្រងដោយរដ្ឋ ឱសថស្ថានក្នុងតំបន់ គ្លីនិកផ្នែកផ្លូវដង្ហើម ឬដោយអ្នកផ្តល់សេវាថែទាំសុខភាព។

សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបទទួលបានការធ្វើតេស្តរកជំងឺ COVID-19 សូមចូលទៅកាន់ **covid.ri.gov/testing**។

12/10/2021